CITY OF
LONG BEACH

# សេចក្តីប្រកាសពត៌មាន

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

ទំនាក់ទំនង: មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ,
562.570.NEWS, jic@longbeach.gov

សំរាប់ផ្សព្វផ្សាយបន្ទាន់

# ក្រុមប្រឹក្សាក្រុង ពន្យាពេលជំនួយបណ្តោះអាសន្នសំរាប់ការផាកពិន័យបោសសំអាតផ្លូវ ទៅដល់ថ្ងៃទី១៨ ខែឧសភា

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា – កាលពីម្សិលមិញ ក្រុមប្រឹក្សាក្រុងឡុងប៊ីឆ បានពន្យារពេល ការផ្អាកជាបណ្តោះអាសន្ននៃការផាកពិន័យបោសសំអាតផ្លូវ ដែលបានគ្រោង ថានឹងត្រូវចាប់ផ្តើមធ្វើបន្តវិញ នៅថ្ងៃទី ៤ ខែឧសភា។ ជាការជំនួសវិញ បុគ្គលិកក្រុងនឹងចាប់ផ្តើមចេញសេចក្តីជូនដំណឹង ស្តីពីយានយន្តចាប់ផ្តើមនៅថ្ងៃទី ៤ ខែឧសភា ហើយការអនុវត្តន៍ច្បាប់នឹងចាប់ផ្តើមនៅថ្ងៃទី ១៨ ខែឧសភា គឺថ្ងៃច័ន្ទដែលបន្ទាប់ពីការផុតកំណត់ នៃបទបញ្ជា "មានសុវត្ថិភាពជាង ពេលនៅផ្ទះ"។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “យើងមានសេចក្តីរីករាយ ក្នុងការបន្តផ្តល់នូវជំនួយចតរថយន្តនេះ ជាពិសេសសម្រាប់សង្កាត់ដែលទទួលរងផលប៉ះពាល់កន្លែងចតរថយន្ត សំរាប់រយៈពេលជិតមួយខែទៀត។ ក្នុងរយៈពេលពីរបីសប្តាហ៍ យើងនឹងត្រូវត្រឡប់ទៅរកកម្មវិធីដ៏ទៀងទាត់ បន្ថែមទៀត ដើម្បីធានាបាននូវសុខភាពសហគមន៍ និងគុណភាពទឹក”។

នៅក្នុងសង្កាត់ជាច្រើន កង្វះខាតនៃការបោសសំអាតតាមដងផ្លូវ បានបណ្តាលអោយមាននូវការប្រមូលផ្តុំ ឬកើនឡើងនូវដីល្បាប់ និងកំទេចកំទី ដែលបង្ករអោយមានគ្រោះថ្នាក់ដល់សមត្ថភាពរបស់ទីក្រុង ក្នុងការបំពេញតាមស្តង់ដារជាតិ សម្រាប់ផ្លូវទឹកស្អាត។ ការបោសសំអាតតាមដងផ្លូវ គឺជាសេវាកម្មសុខភាពមួយ

ដ៏សំខាន់ ដែលជួយលុបបំបាត់ការបំពុលដែលមានសក្តានុពល ពីការលាងសំអាតចូលទៅក្នុងមហាសមុទ្រ ឬទន្លេ។ ដងផ្លូវទាំងឡាយ អាចត្រូវបានគេបោសសំអាតយ៉ាងមានប្រសិទ្ធិភាព នៅពេលណាដែលរថយន្តទាំងឡាយនៅឆ្ងាយពីផ្លូវ នៃអ្នកបោស។

ចាប់ពីថ្ងៃទី ៤ ខែឧសភា បុគ្គលិកនៃមន្ទីរសាធារណៈការ នឹងដាក់នូវការក្រើនរំលឹកនានា លើយានយន្តណាមួយ ដែលមិនត្រូវបានផ្លាស់ប្តូរទីកន្លែង ឬបើកបរចេញ។ ការក្រើនរំលឹកទាំងនេះ នឹងធ្វើការណែនាំដល់ប្រជាពលរដ្ឋ អំពីការរង់ចាំសកម្មភាពអនុវត្តច្បាប់ ចំពោះការខកខានក្នុងការផ្លាស់ប្តូរទីកន្លែងយានយន្តរបស់ពួកគេ, ធនធានចតរថយន្តដែលមាននៅក្នុងទីក្រុង ហើយការអនុវត្តន៍ច្បាប់ នឹងត្រូវចាប់ផ្តើមអនុវត្តឡើងវិញនៅថ្ងៃទី ១៨ ខែឧសភានេះ។ ព័ត៌មាននេះនឹងត្រូវធ្វើអោយមាន ឬផលិតជាភាសាអង់គ្លេស អេស្ប៉ាញ ខ្មែរ និងតាកាឡុក ហើយបុគ្គលិកទីក្រុងនឹងអភិវឌ្ឍន៍នូវផែនការ ក្នុងការចែករំលែកព័ត៌មានអោយបានទូលំទូលាយ។

រាល់ការអនុវត្តន៍ច្បាប់នៅតាមកន្លែងចតរថយន្តផ្សេងៗទៀត រាប់បញ្ចូលទាំងចំណតរថយន្តម៉ែត្រ ឬកំណត់នាទីចត និងតាមចិញ្ចើមថ្នល់ដែលមានពណ៌ក្រហម ពណ៌ស និងពណ៌ខៀវ នឹងបន្តរដូចធម្មតាឡើងវិញ។ ការពង្រឹងច្បាប់នេះ គឺជាការចាំបាច់ ដើម្បីការពារសុវត្ថិភាពសាធារណៈ ជាជំនួយដល់អ្នកឆ្លើយតបដំបូង និងធានាអោយមាននូវកន្លែងចតរថយន្ត ដែលអាចដំណើរការចេញចូល ចតបាន។

ជាផ្នែកមួយ នៃការបន្តរកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយផលប៉ះពាល់កន្លែងចតរថយន្ត ដែលបង្ករឡើងដោយជំងឺ COVID-19, ទីក្រុងឡុងប៊ីចបានបង្កើតនូវកន្លែងចតចំនួន 4,307 កន្លែង។ ទាំងអស់នេះមាន កន្លែងចតនៅលើឆ្នេរចំនួនបី, រចនាសម្ព័ន្ធចតរថយន្តចំនួនប្រាំពីរ, បណ្ណាល័យចំនួនប្រាំមួយ និងសាលាចំនួនបី។ មកទល់ពេលនេះ លិខិតអនុញ្ញាតចតរថយន្តចំនួន 1,204 ច្បាប់ ត្រូវបានចេញ។ បញ្ជីពេញលេញនានា នៃជំរើសចតរថយន្តដោយឥតគិតថ្លៃ ចំនួនជិត ២០ មាននៅ ទីនេះ។

សំរាប់ព័ត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងព័ត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីចកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា: longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

###